ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

**លេខ និងឈ្មោះសំណុំរឿង : ៩៤/០៨ - សាប ខេមហ្សូល**

**កាលបរិច្ឆេទនៃសេចក្តីបង្គាប់ : ថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៨**

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា៣១៣នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក : **ឈីវ ភិរម្យ**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត : **លីវ សុវណ្ណា**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ : **អាំង អេងថុង**

## ភាគីនៃវិវាទ

១-ភាគីនិយោជក

ឈ្មោះ : **ក្រុមហ៊ុន សាប ខេមហ្សូល ខូ អិលធីឌី**

អាសយដ្ឋាន : ភូមិត្រពាំងគល់ ឃុំកន្ទោក ស្រុកអង្គស្នួល ខេត្តកណ្តាល

ទូរស័ព្ទ :០១២ ៦៧៦ ០៥៦ ទូរសារលេខ : គ្មាន

តំណាងភាគីនិយោជក :

១-លោក មាន ដារ៉ា តំណាងក្រុមហ៊ុន

២- ភាគីកម្មករនិយោជិត

ឈ្មោះ : **សហព័ន្ធសហជីពកម្មករកម្ពុជា_សហជីពកម្មកររោងចក្រ សាប ខេមហ្សូល**

អាស័យដ្ឋាន : ភូមិត្រពាំងគល់ ឃុំកន្ទោក ស្រុកអង្គស្នួល ខេត្តកណ្តាល

ទូរស័ព្ទ : ០៥ ៩២៩ ៤០៤ ទូរសារ : គ្មាន



មជ្ឈមណ្ឌលភ្នំពេញ អគារ A បន្ទប់លេខ ៣៣១ វិថីសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ។ ទូរស័ព្ទ/ទូរសារ : ០២៣ ២២០ ៧៩៣
Phnom Penh Center (A), Room 331, Sothearos Blvd, Sangkat Tonle Basak, Khan Chamkar Morn, Phom Penh · Tel/Fax: 023 220 79...
Email: secretariat@arbitrationcouncil.org· Website: www.arbitrationcouncil.org

តំណាងកម្មករនិយោជិត :

១- លោក ចាយ សុភា អគ្គលេខាធិការរងសហព័ន្ធសហជីពកម្មករកម្ពុជា

២- លោក ជន សម្បត្តិ ប្រធានសហជីពកម្មករនិយោជិតរោងចក្រ សាប ខេហ្សល

៣- លោក យុត វណ្ណៈ លេខាសហជីពកម្មករនិយោជិតរោងចក្រ សាប ខេហ្សល

៤- លោក ស៊ុន ប៊ុនហៀង ហិរញ្ញិកសហជីពកម្មករនិយោជិតរោងចក្រ សាប ខេហ្សល

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១-កម្មករទាមទារឱ្យក្រុមហ៊ុនកាត់ប្រាក់ភាគទានសហជីពកម្មករកម្ពុជា ចំនួន ៥៩៥ នាក់។ ភាគីក្រុមហ៊ុន សុំពេលពិចារណាជាមួយថៅកែមួយសប្តាហ៍។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ)(មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខ ០៩៩ សកបយ ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃ ប្រកាស លេខ ០៩៩ សកបយ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខ ០៧៦/០៧ កកបវ./ប្រក ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០០៧ (អាណត្តិទី៥)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី ១២ ផ្នែកទី២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជា លេខ ៣៥៥/០៨ ក.ប/ក.ណ ចុះថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០០៨ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០០៨។

## សវនាការ និង សង្ខេបនីតិវិធី

**ទីកន្លែងសវនាការ :** ក្រុមប្រឹក្សាអាជ្ញាកណ្តាល មជ្ឈមណ្ឌលភ្នំពេញ អគារ A វិថីសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ។

**កាលបរិច្ឆេទសវនាការ :** ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០០៨ (វេលាម៉ោង ៨:០០នាទី ដល់ម៉ោង ១០:៣០នាទី)។

បញ្ហានៃនីតិវិធី :

នៅថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០០៨ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកណ្តាល បានទទួលពាក្យបណ្តឹងសារទុក្ខពីសហព័ន្ធសហជីពកម្មករកម្ពុជា។ នៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០៨ មន្ត្រីដោះស្រាយវិវាទការងារ

របស់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកណ្តាល បានធ្វើការផ្សះផ្សាវិវាទការងាររួមចំនួន ៥ ចំណុច។ ការផ្សះផ្សាបានទទួលលទ្ធផលសះជាចំនួន ៤ ចំណុច នៅសល់ ១ ចំណុច ត្រូវបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាលដោះស្រាយបន្តតាមនីតិវិធីច្បាប់។

នៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៨ របាយការណ៍ដោះស្រាយវិវាទការងារមិនសះជាចំនួន ១ ចំណុចនេះ ត្រូវបានបញ្ជូនមកដល់លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ហើយភាគីទាំងពីរនៃវិវាទបានមកជ្រើសរើសអាជ្ញាកណ្តាលតាមច្បាប់។ បន្ទាប់មកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានអញ្ជើញភាគីវិវាទទាំងពីរឱ្យចូលរួមសវនាការនៅថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០៨ វេលាម៉ោង ៩ ព្រឹក នៅក្រុមប្រឹក្សាអាជ្ញាកណ្តាល ដើម្បីដំណើរការអាជ្ញាកណ្តាលដោះស្រាយវិវាទដែលមិនទាន់សះជានេះ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានលើកទឹកចិត្តដល់ភាគីទាំងពីរឱ្យបន្តការចរចាទាំងនៅក្នុងសវនាការ ទាំងនៅក្នុងសហគ្រាស ដើម្បីស្វែងរកដំណោះស្រាយមួយតាមរយៈការផ្សះផ្សា។ ក៏ប៉ុន្តែភាគីទាំងពីរនៅតែមិនអាចយោគយល់គ្នា និងមិនអាចទទួលបានលទ្ធផលសះជានឹងគ្នាទេ។

**ភស្តុតាង**

**សាក្សី និង អ្នកជំនាញក្រៅពីភាគី ៈគ្មាន**

**ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

ក- ឯកសារបានទទួលពីភាគីនិយោជក ៖

១- លិខិតផ្ទេរសិទ្ធិជូនលោក មាន ដារ៉ា ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០៨។

២- សំណើរសុំកែសម្រួលលើបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន សាប ខេហ្សេល ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ ២០០២។

៣- បទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន សាប ខេហ្សេល ចុះបញ្ជិកាលេខ ០៤៩ សកបយ.ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០២។

៤- ប័ណ្ណប៉ាតង់របស់ក្រុមហ៊ុន សាប ខេហ្សេល លេខ ១៣-២០០៨ សពដ.កណ ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ ២០០៨។

៥- វិញ្ញាបនប័ត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម ក្រុមហ៊ុន សាប ខេហ្សេល លេខ ២៣០១ ពណ. ចបព ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០៨។

៦- វិញ្ញាបនប័ត្របញ្ជាក់ការចុះបញ្ជីក្នុងប្រព័ន្ធអនុគ្រោះពាណិជ្ជកម្មក្រុមហ៊ុន សាប ខេហ្សេល ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០០៧។

៧- វិញ្ញាបនប័ត្រចុះបញ្ជីអាករលើតម្លៃបន្ថែមក្រុមហ៊ុន សាប ខេហ្សុល ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ ២០០៧។

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត :**

១- លិខិតជូនដំណឹងអំពីការបោះឆ្នោតបង្កើតសហជីពកម្មករនិយោជិតរោងចក្រ សាប ខេហ្សុល លេខ ២០០៦ សសកក ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០០៨។

២- សំណើរសុំកាត់ប្រាក់ និងបញ្ជីឈ្មោះកម្មករ ដែលឱ្យក្រុមហ៊ុនកាត់ប្រាក់ភាគទានពីសមាជិកសហជីព ១០០០រៀល ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០០៨។

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន សាប ខេហ្សុល លេខ ៣៥៩/០៨ កប/ កណ ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៨។

២- កំណត់ហេតុផ្សះផ្សាវិវាទការងាររួមក្រុមហ៊ុន សាប ខេហ្សុល ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៨។

**ឃ-ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល**

១- លិខិតអញ្ជើញភាគីក្រុមហ៊ុនចូលរួមសវនាការ លេខ ៤៦៥ កប/អក/វក/លកអ. ចុះថ្ងៃទី២៣ ខែ កក្កដា ឆ្នាំ២០០៨។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការលេខ ៤៦៦ កប/អក/វក/លកអ.ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨។

សន្តិហេតុ

-ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម

-ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និង ភាគីនិយោជក

-ក្រោយពីបានពិនិត្យឯកសារបន្ថែម

**ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា :**

- សហជីពកម្មករនិយោជិតរោងចក្រ សាប ខេហ្សុល ទាមទារឱ្យក្រុមហ៊ុនកាត់ប្រាក់ភាគទានសហជីព មួយខែចំនួន ១០០០ រៀលក្នុងម្នាក់ ចំពោះកម្មករ ដែលជាសមាជិកសហជីព ហើយស្ម័គ្រចិត្តឱ្យ ក្រុមហ៊ុនកាត់ ពីព្រោះសហជីពបានទទួលការចុះបញ្ជិកាពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រួចហើយ គឺ បញ្ជិកាលេខ ២០០៦ សសកក ចុះថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០០៨។

- សហជីពបានលើកឡើងនៅក្នុងសវនាការថា សហជីពកម្មករនិយោជិតរោងចក្រ សាប ខេហ្សុល បានធ្វើលិខិតស្នើសុំទៅក្រុមហ៊ុនឱ្យជួយកាត់ប្រាក់ភាគទានសហជីពនេះ ប៉ុន្តែនិយោជកបដិសេធក្នុងការកាត់ប្រាក់វិភាគទាននេះជូនសហជីព។
- សហជីពកម្មករនិយោជិតរោងចក្រ សាប ខេហ្សុល បានផ្តល់បញ្ជីឈ្មោះកម្មករ ដែលជាសមាជិកសហជីព ហើយស្ម័គ្រចិត្តឱ្យក្រុមហ៊ុនកាត់ភាគទានសហជីពជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាល និងក្រុមហ៊ុនតាមកាលបរិច្ឆេទកំណត់របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី០៤ ខែសីហា ឆ្នាំ២០០៨។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានទុករយៈពេលដល់ថ្ងៃទី០៧ ខែសីហា ឆ្នាំ២០០៨ ដើម្បីឱ្យក្រុមហ៊ុនពិនិត្យ និងធ្វើការចរចារសំរុះសំរួលគ្នាបន្តនៅឯរោងចក្រ និងធ្វើការជំទាស់ ប្រសិនបើក្រុមហ៊ុនពិនិត្យឃើញថា បញ្ជីឈ្មោះកម្មករនោះមិនត្រឹមត្រូវ។ ប៉ុន្តែភាគីក្រុមហ៊ុនមិនបានធ្វើការជំទាស់ទៅនឹងឯកសារនេះទេ។
- ចំណែកឯភាគីក្រុមហ៊ុន បានលើកឡើងនៅក្នុងសវនាការថា ក្រុមហ៊ុនមិនអាចជួយកាត់ប្រាក់ភាគទានសហជីពនេះបានទេ ពីព្រោះក្រុមហ៊ុនមិនធ្លាប់កាត់តាំងពីដើមរៀងមក។

## ហេតុផលនៃសេចក្តីសម្រេច

មាត្រា ២៨១ នៃច្បាប់ការងារចែងថា *"ត្រូវហាមឃាត់មិនឱ្យនិយោជកគ្រប់រូបធ្វើការកាត់ប្រាក់ឈ្នួលនៃកម្មករនិយោជិត ដើម្បីបង់ភាគទានសហជីព និងហាមឃាត់មិនឱ្យនិយោជកគ្រប់រូបបង់ប្រាក់ភាគទាននេះជំនួសកម្មករនិយោជិត។"*

ប៉ុន្តែ មាត្រា ១២៩ វាក្យខ័ណ្ឌទី ២ នៃច្បាប់ការងារចែងថា........*កម្មករនិយោជិតអាចអនុញ្ញាតឱ្យកាត់ប្រាក់ឈ្នួលរបស់ខ្លួន ដើម្បីបង់ភាគទានសហជីព ដែលខ្លួនជាសមាជិក។ ការអនុញ្ញាតនេះត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងអាចបដិសេធវិញបានគ្រប់ពេលវេលា"* ។

បន្ថែមលើមាត្រានេះ ប្រការ ៥ នៃប្រកាសលេខ ៣០៥ ឆ្នាំ២០០១ របស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា បានចែងថា *"កម្មករនិយោជិតទាំងអស់ ដែលជាសមាជិកសហជីពអាចស្នើសុំជាលាយលក្ខណ៍អក្សរក្នុងរយៈពេល១៥ថ្ងៃមុន ដើម្បីឱ្យនិយោជកកាត់ប្រាក់ឈ្នួលរបស់ខ្លួន ដើម្បីបង់ភាគទានសហជីព ដែលខ្លួនជាសមាជិកស្របតាមមាត្រា ១២៩ នៃច្បាប់ការងារ"* ។

នៅក្នុងសេចក្តីបង្គាប់មុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានសម្រេចថា ខ្លឹមសារនៃមាត្រា ២៨១ នៃច្បាប់ស្តីពីការងារ ចែងឡើងក្នុងគោលបំណង ដើម្បីការពារសិទ្ធិកម្មករនិយោជិត និងហាមឃាត់និយោជកកុំឱ្យធ្វើសកម្មភាពជ្រៀតជ្រែកក្នុងការធ្វើឱ្យសហជីពនៅក្រោមឥទ្ធិពលរបស់ខ្លួន ដូចមានចែងក្នុងមាត្រា ២៨០ នៃច្បាប់ស្តីពីការងារ។ (សូមមើលសេចក្តីបង្គាប់ក្រុមប្រឹក្សារអាជ្ញាកណ្តាល លេខ ០៥/០៣-ផប វិន្ទុ ហេតុផលនៃសេចក្តី

សម្រេចចំណុចវិវាទទី១, លេខ ៦២/០៤- អ៊ី ស៊ីន ហេតុផលនៃសេចក្តីសម្រេច ចំណុចវិវាទទី៨, លេខ ៩៤/០៤-អ៊ីថីនីធី អឹកែរឹល ហេតុផលនៃសេចក្តីសម្រេចចំណុចវិវាទទី៤, លេខ ៩៥/០៦-អេ អាយ អេ ហេតុផលនៃសេចក្តីសម្រេច ចំណុចវិវាទទី១២ និងលេខ ១៦/០៥-ញូភាញ់ វើលគ្រេត ខេមបូឌា ហេតុផលនៃសេចក្តីសម្រេចចំណុចវិវាទទី១១ ។)

ក៏ប៉ុន្តែក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញផងដែរថា ច្បាប់ស្តីពីការងារមិនហាមឃាត់និយោជកធ្វើការកាត់ប្រាក់ឈ្នួលរបស់កម្មករនិយោជិត ដើម្បីបង់ភាគទានសហជីពទេ ក្នុងករណីដែលកម្មករនិយោជិតផ្តល់ការអនុញ្ញាតជាលាយលក្ខណ៍អក្សរឱ្យនិយោជកធ្វើដូច្នេះ។ ក្នុងករណីនេះ និយោជកមានកាតព្វកិច្ចកាត់ប្រាក់ឈ្នួលកម្មករនិយោជិត ដើម្បីបង់ភាគទានសហជីព។

នៅក្នុងសេចក្តីបង្គាប់មុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានសម្រេចយ៉ាងស៊ីសង្វាក់គ្នាថា បង្គាប់ឱ្យនិយោជកកាត់ប្រាក់ឈ្នួលពីកម្មករនិយោជិតដែលជាសមាជិកសហជីព ហើយកម្មករនិយោជិតនោះស្ម័គ្រចិត្តឱ្យកាត់ ដើម្បីបង់ភាគទានជូនសហជីព តាមការស្នើសុំជាលាយលក្ខណ៍អក្សរ។ (សូមមើលសេចក្តីបង្គាប់លេខ ០៣/០៣ តុង ហ្កា ហេតុផលនៃសេចក្តីសម្រេច ចំណុចវិវាទទី៩, លេខ ៦០/០៧ ស៊ូត វ៉ៅ ហេតុផលនៃសេចក្តីសម្រេច ចំណុចវិវាទទី៧, លេខ ៦៥/០៧-ជា ហ្វុង ហេតុផលនៃសេចក្តីសម្រេច ចំណុចវិវាទទី២ និង លេខ ៦១/០៨-ហ្វូកឹស ហ្វូតវៀ ហេតុផលនៃសេចក្តីសម្រេច ចំណុចវិវាទទី២) ។

នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏យល់ស្របទៅនឹងការសម្រេចរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលមុនៗខាងលើដែរ។

ហេតុដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចឱ្យនិយោជកកាត់ប្រាក់ឈ្នួលចំនួន ១០០០រៀល ពីកម្មករនិយោជិត ដែលជាសមាជិកសហជីពកម្មករនិយោជិតរោងចក្រ សាប ខេហ្សល ហើយស្ម័គ្រចិត្តឱ្យក្រុមហ៊ុនកាត់ ដើម្បីបង់ភាគទានជូនសហជីពកម្មករនិយោជិតប្រចាំក្រុមហ៊ុន។

## សម្រេច និង បង្គាប់

-បង្គាប់ឱ្យនិយោជកកាត់ប្រាក់ឈ្នួលចំនួន ១០០០ រៀល លើប្រាក់ឈ្នួលកម្មករនិយោជិត ដែលជាសមាជិកសហជីពកម្មករនិយោជិតរោងចក្រ សាប ខេហ្សល ហើយដែលស្ម័គ្រចិត្តឱ្យក្រុមហ៊ុនកាត់ផង ដើម្បីបង់ភាគទានជូនសហជីពកម្មករនិយោជិតរោងចក្រ សាប ខេហ្សល។

ប្រភេទនៃសេចក្តីបង្គាប់ : សេចក្តីបង្គាប់ជាប់កាតព្វកិច្ច

*សេចក្តីបង្គាប់នេះនឹងក្លាយជាស្ថាពរភ្លាម ហើយអនុវត្តចំពោះភាគីតែម្តង បន្ទាប់ពីសេចក្តីបង្គាប់នេះចេញទៅ ដោយភាគីទាំងពីរបានយល់ព្រមជ្រើសរើសយកសេចក្តីបង្គាប់នេះ នៅថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០០៨។*

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក :

ឈ្មោះ : **ឈីវ គិរម្យ**

ហត្ថលេខា: -----------------------------------

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត :

ឈ្មោះ : **លីវ សុវណ្ណា**

ហត្ថលេខា: -----------------------------------

ប្រធានក្រុមអាជ្ញាកណ្តាល :

ឈ្មោះ : **អាំង អេងថុង**

ហត្ថលេខា: -----------------------------------